ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

គណៈកម្មការប្រឹក្សាការងារ

សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ

កាលពីព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបើកកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារអាណត្តិទី៨ លើកទី១៦ ដើម្បីចាប់ផ្តើមជាផ្លូវការនូវដំណាក់ កាលទី ៣ នៃការចរចាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ ឆ្នាំ២០១៨។ តាមរយៈការពិភាក្សារបស់សមាជិកគណៈកម្មការប្រឹក្សាការងារ ដែលមានសមាសភាពមកពី ភាគីកម្មករនិយោជិត ភាគីនិយោជក និងភាគីរាជរដ្ឋាភិបាល កិច្ចប្រជុំសម្រេចបានលទ្ធផលដូចខាងក្រោម៖

១. បង្កើតក្រុមការងារបច្ចេកទេសត្រីភាគី ដែលមានសមាសភាពចំនួន ១៦រូប មកពីភាគីនីមួយៗ ដើម្បីពិភាក្សាប្រាក់ឈ្នួលអប្បបរមា។ ក្រុមការងារនេះនឹងចាប់ផ្តើមប្រជុំពិភាក្សាចាប់ពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ នេះតទៅ។

២. ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យបែបសង្គម (ស្ថានភាពគ្រួសារ អត្រាអតិផរណា និងការចំណាយក្នុងការរស់នៅ) និងលក្ខណៈវិនិច្ឆ័យបែបសេដ្ឋកិច្ច (ផលិតភាព ភាពប្រកួតប្រជែងរបស់ប្រទេស ស្ថានភាព ទីផ្សារការងារ និងកម្រិតចំណេញរបស់វិស័យ) ធ្វើជាមូលដ្ឋានក្នុងការពិភាក្សា ព្រមទាំងលើកជាអនុសាសន៍ដល់គណៈកម្មការប្រឹក្សាការងារដើម្បីពិនិត្យសម្រេច។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត និយោជក អង្គការវិជ្ជាជីវៈ អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧

ប្រធានគណៈកម្មការប្រឹក្សាការងារ	អនុប្រធានគណៈកម្មការប្រឹក្សាការងារ ភាគីតំណាងនិយោជក	អនុប្រធានគណៈកម្មការប្រឹក្សាការងារ ភាគីតំណាងកម្មករនិយោជិត
បណ្ឌិត **អ៊ុត សំហោង**	ឧកញ៉ាបណ្ឌិត **ណាង សុធី**	**ជួន ម៉ុងឈុល**